# ព្រះរាជក្រឹត្យ

នស/រកត/០៥១៩/៥៤៩

## ស្តីពី

## ឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

ចូល លេខៈ ៤២១១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ពោហនាស គម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៦/៦១៦ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញសម្រាប់អាណត្តិ៣ឆ្នាំលើកទី៧ (ឆ្នាំ២០១៦ ដល់ឆ្នាំ ២០១៩)
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ ឯកឧត្តម អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

# ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ព្រះរាជក្រឹត្យនេះ មានគោលបំណងបង្កើត និងកំណត់ឱ្យប្រើប្រាស់នូវឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលរួមមាន ឯកសណ្ឋានរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ឯកសណ្ឋានរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងឯកសណ្ឋានរបស់គណៈលេខាធិការនៃសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

## ជំពូកទី២

## ឯកសណ្ឋានរបស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គ

**មាត្រា ២.-**

ឯកសណ្ឋានរបស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គ គឺអាវផាយគ្របពីលើអាវកុតពណ៌ខ្មៅ ឡេវមាសត្រាព្រះរាជសង្ហា ខោជើងវែងពណ៌ខ្មៅ ស្បែកជើងឃ្លុប កន្ថីពណ៌ខ្មៅ សម្រាប់ប្រធាន ឬសមាជិកក្រុមប្រឹក្សាធម្មនុញ្ញជាបុរស និងអាវកុតពណ៌ខ្មៅ ឡេវមាសត្រាព្រះរាជសង្ហា សំពត់សំឡុយពណ៌ខ្មៅ ស្បែកជើងអេស្កាប៉ុងពណ៌ខ្មៅ សម្រាប់ប្រធាន ឬសមាជិកក្រុមប្រឹក្សាធម្មនុញ្ញជានារី។

### ក- អាវផាយរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

- មានដៃវែង ពណ៌ក្រហមក្រមៅចាស់ គ្មានឡេវ សម្រុងចុះត្រឹមស្មងជើង មានក្បាច់ភ្ញីទេសពណ៌មាសក្នុងទម្រង់ជាចង្វាយប្រទាក់ មានក្បាច់ទម្រង់ផ្កាឈូកនៅចំកណ្តាល។ ក្បាច់ភ្ញីទេសនេះ ព័ទ្ធលើដើមកសំយុងចុះតាមដើមទ្រូងផ្នែកខាងមុខ រហូតដល់ចុងជាយអាវ និងព័ទ្ធជាយអាវផ្នែកខាងក្រោយកំភួនជើងគម្រប់បានមួយជុំជាយអាវផាយ។ ក្បាច់ភ្ញីទេសនៅជាយអាវផាយនេះ មានអមសងខាងដោយខ្សែស្រយពណ៌មាស នៅកណ្តាលខ្សែទឹកមាស។ នៅលើផ្ទៃអាវទាំងមូល មានរំលេចនូវផ្កាឈូកពណ៌មាសតូចៗ (ផ្កាបណ្តែត) តម្រៀបគ្នាដោយរៀបរយល្អ
- នៅក្នុងរង្វង់ក្បាច់ភ្ញីទេសជាយអាវផាយត្រង់ដើមទ្រូងខាងឆ្វេង មានរំលេចនូវផ្កាឈូកជាមួយគម្ពីរ [illegible]ផ្កាកេតនភណ្ឌនៅព្រះហស្តខាងឆ្វេងទាំងពីររបស់ព្រះព្រហ្ម។ ចំណែកនៅក្នុងរង្វង់ក្បាច់ភ្ញីទេសជាយ

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

អាវផាយត្រង់ដើមទ្រូងខាងស្តាំ មានរំលេចនូវពួចទឹកនិងផ្កាំ ដែលជាកេតនភណ្ឌនៅព្រះហស្តខាងស្តាំទាំងពីររបស់ព្រះព្រហ្ម

– នៅដើមដៃទាំងពីរនៃអាវផាយ និងនៅចុងដៃអាវទាំងពីរនៃអាវផាយ មានព័ទ្ធក្បាច់ភ្ញីទេសមួយជុំ ដែលមានទម្រង់ និងក្បាច់រចនាដូចគ្នានឹងក្បាច់ភ្ញីទេស ដែលប្រើជាជាយអាវផាយដែរ។

រូបគំនូរអាវផាយរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ មានគំរូដូចក្នុងឧបសម្ព័ន្ធទី១ នៃព្រះរាជក្រឹត្យនេះ។

**ខ– អាវផាយរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ**

អាវផាយរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គ មានសណ្ឋានទ្រង់ទ្រាយដូចគ្នានឹងអាវផាយរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញដែរ ប្លែកតែនៅលើផ្ទៃអាវទាំងមូលមិនមានរំលេចនូវផ្កាឈូកតូចៗពណ៌មាស (ផ្កាបណ្តែត)។

រូបគំនូរអាវផាយរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានគំរូដូចក្នុងឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យនេះ។

រូបគំនូរផ្កាឈូកពណ៌មាសលើផ្ទៃអាវផាយរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ និងគំនូរកេតនភណ្ឌព្រះព្រហ្ម ដែលរចនានៅលើក្បាច់ភ្ញីទេសជាយអាវផាយផ្នែកដើមទ្រូងទាំងពីរ ជាឯកសណ្ឋានរបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានគំរូដូចក្នុងឧបសម្ព័ន្ធទី៣ នៃព្រះរាជក្រឹត្យនេះ។

**មាត្រា ៣.–**

ក្រុមប្រឹក្សាធម្មនុញ្ញ អាចប្រើផងដែរនូវកន្លាស់និមិត្តសញ្ញាសម្គាល់ក្រុមប្រឹក្សាធម្មនុញ្ញ ជាមួយអាវផាយនេះ។ ការប្រើកន្លាស់និមិត្តសញ្ញាសម្គាល់ក្រុមប្រឹក្សាធម្មនុញ្ញ គឺប្រើនៅលើអាវផាយផ្នែកទ្រូងខាងឆ្វេង។

## ជំពូកទី៣

## ឯកសណ្ឋានរបស់គណៈលេខាធិការនៃសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

**មាត្រា ៤.–**

ឯកសណ្ឋានរបស់គណៈលេខាធិការនៃសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺអាវផាយ គ្របពីលើអាវកុតពណ៌ដូចពណ៌សំបកផ្លែមង្ឃុត ខ្សែរមាសក្រោមព្រះរាជសង្ហា ខោជើងវែងពណ៌ដូចពណ៌អាវ ស្បែកជើងឃ្លុប កខ្លីពណ៌ខ្មៅ សម្រាប់លេខាធិការ ឬជំនួយការលេខាធិការ

ROYAUME DU CAMBODGE
ក្រសួងព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

ជាប្រុស និងអាវកុតពណ៌ដូចពណ៌សំបកផ្លែមង្ឃុត ឡេវមាសត្រាព្រះរាជសង្ហា សំពត់សំឡូយពណ៌ដូចពណ៌អាវ ស្បែកជើងអេស្កាប៉ុងពណ៌ខ្មៅ សម្រាប់លេខាធិការ ឬជំនួយការលេខាធិការ ជានារី។

**គ-អាវផាយរបស់លេខាធិការ**

– មានដៃវែង ពណ៌ដូចពណ៌កាកអំពៅ គ្មានឡេវ សម្រុងចុះត្រឹមស្មងជើង មានក្បាច់ភ្ញីទេសពណ៌មាស ក្នុងទម្រង់ជាសន្លឹកឈើតម្រៀបលើគ្នា ជាជួរបញ្ឈិតមានទងចុះក្រោម។ ក្បាច់ភ្ញីទេសនេះ ព័ទ្ធលើដើមក សំយុងចុះតាមដើមទ្រូងផ្នែកខាងមុខរហូតដល់ចុងជាយអាវ និងព័ទ្ធជាយអាវផ្នែកខាងក្រោយកំភួនជើងគម្រប់បានមួយជុំជាយអាវផាយ។ ក្បាច់ភ្ញីទេសនៅជាយអាវផាយនេះ មានអមសងខាងដោយខ្សែសយពណ៌មាស នៅកណ្ដាលខ្សែទឹកមាស

– នៅលើក្បាច់ភ្ញីទេសជាយអាវផាយផ្នែកដើមទ្រូងសងខាង មានផ្កាឈូកពណ៌មាសចំនួនពីរ ទម្រង់ដូចផ្កាឈូកបណ្ដែត ដែលប្រើលើផ្នែអាវផាយរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

– នៅដើមដៃទាំងពីរនៃអាវផាយ និងនៅចុងដៃអាវទាំងពីរនៃអាវផាយ មានក្បាច់ភ្ញីទេសព័ទ្ធមួយជុំ ដែលក្បាច់ភ្ញីទេសនេះ មានទម្រង់ និងក្បាច់រចនាដូចគ្នានឹងក្បាច់ភ្ញីទេសដែលប្រើជាជាយអាវផាយដែរ។

រូបគំនូរអាវផាយរបស់លេខាធិការ មានគំរូដូចក្នុងឧបសម្ព័ន្ធទី៤ នៃព្រះរាជក្រឹត្យនេះ។

**ខ-អាវផាយរបស់ជំនួយការលេខាធិការ**

អាវផាយរបស់ជំនួយការលេខាធិការ មានសណ្ឋានទ្រង់ទ្រាយដូចនឹងអាវផាយរបស់លេខាធិការដែរ ប្លែកតែនៅលើក្បាច់ភ្ញីទេសជាយអាវផាយផ្នែកទ្រូងសងខាង មិនមានរំលេចផ្កាឈូកពណ៌មាសចំនួនពីរនោះឡើយ។

រូបគំនូរអាវផាយរបស់ជំនួយការលេខាធិការ មានគំរូដូចក្នុងឧបសម្ព័ន្ធទី៥ នៃព្រះរាជក្រឹត្យនេះ។

**មាត្រា ៥.-**

លេខាធិការ ឬជំនួយការលេខាធិការនៃសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សា-ធម្មនុញ្ញ អាចប្រើផងដែរ នូវកន្លាស់និមិត្តសញ្ញាសម្គាល់មន្ត្រីអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញជាមួយអាវផាយនេះ។ ការប្រើប្រាស់កន្លាស់នេះ គឺប្រើនៅលើអាវផាយផ្នែកទ្រូងខាងឆ្វេង។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី៣

## របបកំណត់ឯកសណ្ឋានរបស់ក្រុមប្រឹក្សាធម្មនុញ្ញ និងឯកសណ្ឋានរបស់គណៈលេខាធិការ ក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

មាត្រា ៦.-

ត្រូវបានផ្តល់ជូនក្រុមប្រឹក្សាធម្មនុញ្ញ និង គណៈលេខាធិការ នូវឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬ កិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ទៅតាមតម្រូវការជាក់ស្តែង។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

មាត្រា ៧.-

ឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដូចមានកំណត់នៅក្នុងព្រះរាជក្រឹត្យនេះ ត្រូវយកទៅប្រើប្រាស់ភ្លាម ក្រោយពេលព្រះរាជក្រឹត្យចូលជាធរមាន។

មាត្រា ៨.-

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.០៥១៨.៥៣៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៨*

លេខ: ៦១១ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃពុធ ១កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

ឧបសម្ព័ន្ធទី១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៧/៥៧៩

ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨

ស្ដីពីឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

## រូបគំនូរអាវផាយរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ



## រូបគំនូរពង្រីកក្បាច់ភ្ញីទេសជាយអាវផាយ



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨ /៥៤៩
ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨
ស្តីពីឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

## រូបគំនូរអាវផាយរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ



## រូបគំនូរពាច្រីកក្បាច់ភ្ញីទេសជាយអាវផាយ



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឧបសម្ព័ន្ធទី៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨ /៥៤៩
ចុះថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ២០១៨
ស្ដីពីឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

**រូបគំនូរផ្កាឈូកពណ៌មាស (ផ្កាបណ្ដែត) លើអាវផាយរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**



**រូបគំនូរភេគនភណ្ឌព្រះព្រហ្មដែលប្រើនៅលើចង់ក្បាច់ភ្ញីទេសជាយអាវផាយ**



ខាងស្ដាំ



ខាងឆ្វេង

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

ឧបសម្ព័ន្ធទី៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/ ០៥១៨ /៥៧៦
ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨
ស្តីពីឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

## រូបគំនូរអាវផាយរបស់លេខាធិការ



## រូបគំនូរពន្រ្ទិតក្បាច់ភ្ញីទេសជាយអាវផាយ



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឧបសម្ព័ន្ធទី៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៨៩
ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨
ស្តីពីឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

## រូបគំនូរអាវផាយរបស់ជំនួយការលេខាធិការ



## រូបគំនូរពង្រីកក្បាច់ភ្ញីទេសជាយអាវផាយ



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL